# ទូរគមនាគមន៍កម្ពុជា សម្រេចផ្អាកការងារ និងព្យួរប្រាក់បៀវត្សរ៍បណ្ដោះអាសន្នរបស់និយោជិត ៤ រូប

កាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៥ ទូរគមនាគមន៍កម្ពុជា បានចេញសេចក្ដីសម្រេចផ្អាកការងារ និងព្យួរប្រាក់បៀវត្សរ៍បណ្ដោះអាសន្ន និយោជិត ៤ រូប រួមមាន ទី១.លោក ណី សំកុល ប្រធាននាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ, ទី២.លោក ខឹម តេងអឿន អនុប្រធាននាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ, ទី៣.លោកស្រី សោម បូផល្លារី អនុប្រធានការិយាល័យប្រមូលចំណូល និងទារបំណុល, និងទី៤.លោក សែម សំអាង ប្រធានផ្នែកទារបំណុលនៃការិយាល័យប្រមូលចំណូល និងទារបំណុល។

ក្នុងអំឡុងពេលនៃការផ្អាកការងារ និងព្យួរប្រាក់បៀវត្សរ៍នេះ និយោជិតទាំង ៤ រូប ត្រូវមានវត្តមានក្នុងម៉ោងធ្វើការ នៅទីស្នាក់ការកណ្ដាលទូរគមនាគមន៍កម្ពុជា ដើម្បីសហការជាមួយក្រុមការងារអធិការកិច្ចនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងអង្គភាពពាក់ព័ន្ធ ក្នុងការបន្តស្រាវជ្រាវតាមនីតិវិធីនូវបញ្ហាបំណុលរបស់ទូរគមនាគមន៍កម្ពុជា៕